# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## នាយកក្រុមហ៊ុន ហ័រសេងដា ហ្ស៊ីបភើ(ខេម)ខូអិលធីឌី

## កិច្ចព្រមព្រៀង

នៅព្រឹកថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០២០ នៅក្រុមហ៊ុន ហ័រសេងដា ហ្ស៊ីបភើ (ខេម)

បានបើកកិច្ចប្រជុំមួយរវាង ប្រធានរោងចក្រ ជាមួយតំណាងកម្មករក្នុងក្រុមហ៊ុន នឹងប្រធានក្រុមគ្រប់ផ្នែក ស្តីពីការស្នើរសុំព្យួរកិច្ចសន្យាការងារ៕

**កម្មវត្ថុ៖** សំណើរស្នើរសុំព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិត៕

**យោង៖** តាមមាត្រា ៧១ និងមាត្រា ៧២ នៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ។

យោងតាមសេចក្តីប្រកាសរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈលេខ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ស។

សេចក្តីដូចមានចែងក្នុង កម្មវត្ថុ និង យោង ខាងលើនេះ ដោយសារតែរោងចក្រយើងខ្ញុំត្រូវបានលុបចោលការបញ្ជាទិញ និង គ្មានការបញ្ជាទិញពីអតិថិជន ដែលទាក់ទងនិងប៉ះពាល់ពីជម្ងឺរលាកផ្លូវដង្ហើម (COVID-19)។ ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើរសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ២១ នាក់រយៈពេល ២ ខែ ដោយគឹតចាប់ពីថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ០៦ខែ កញ្ញា ឆ្នាំ ២០២០។

ដោយយោងតាមមាត្រា និង ប្រកាស ខាងលើ ភាគីទាំងអស់គ្នាបានឯកភាពគ្នាព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី ០៩ ខែ

កក្កដា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០២០។ ក្រុមហ៊ុនយល់ស្របតាមគោលការណ៍រាជរដ្ឋាភិបាលក្នុងការផ្តល់ឧបត្ថម្ភ ៣០ ដុល្លា អាមេរិចក្នុង ១ខែ ជូនដល់កម្មករនិយោជិត ដោយអនុវត្តតាមប្រកាសរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈលេខ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ស។

កិច្ចប្រជុំបានចប់សព្វគ្រប់នៅថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសសប្បាយរីករាយ។ ភាគីទាំងសងខាងបានឯកភាពគ្នាអនុវត្តលើកិច្ចព្រមព្រៀង និង សូមផ្តិតមេដាយ ចុះហត្ថលេខា ទុកជាភស្តុតាងដូចខាងក្រោម។

ថ្ងៃ សុក្រ ១៣កើត ខែ អាសាឍ ឆ្នាំ ជូត ទោស័ក ពស ២៥៦៤

កំពង់ស្ពឺថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០២០

**នាយកក្រុមហ៊ុន**

ក្រុមហ៊ុន ហ័រសេងដា ហ្ស៊ីបភើ(ខេម)
រដ្ឋបាល+ធនធានមនុស្ស
Admin & HR Department
HUASHENGDA ZIPPER (CAM) CO., LTD.

**ស្នាមមេដាយតំណាងកម្មករ**

ទូច ទិត    នៅ ស្រីអូន